*<u>សេចក្ដីព្រាង-**Draft**</u>*

# **លក្ខន្តិកៈ**

- ដោយធ្លាប់រងការឈឺចាប់សព្វបែបយ៉ាង កាលដែលប្រទេសជាតិស្ថិតនៅក្រោមរណបបរទេស និង ជាពិសេស នៅក្រោមរបបប្រល័យពូជសាសន៍ (១៩៧៥-១៩៧៩)
- ដោយមានបំណងឱ្យការផ្ទេរអំណាចដឹកនាំប្រទេសជាតិ ធ្វើទៅបានរលូន តាមគន្លងប្រជាធិបតេយ្យ
- ដោយយល់ច្បាស់ថា ប្រទេសកម្ពុជាត្រូវឈានដល់របត់កែប្រែមួយយ៉ាងសំខាន់ក្នុងប្រវត្តិសាស្ត្រ

ប្រជាពលរដ្ឋខ្មែរមួយក្រុម ដែលមានទស្សនៈ និងការយល់ឃើញប្រហាក់ប្រហែលគ្នា ពុះពោរដោយឆន្ទៈ និងការប្ដេជ្ញាមោះមុត បានបូជាកំលាំងកាយ ចិត្ត ពិចារណារិះរកវិធីកែប្រែផ្នត់គំនិតមនុស្សក្នុងសង្គម ព្រមដោយមានការពិគ្រោះ យោបល់ ពិភាក្សាជាមួយប្រជាពលរដ្ឋជាច្រើនទៀតរហូតដល់ព្រមព្រៀងគ្នាបង្កើត **គណបក្ស សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ** នៅថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៥ ដើម្បីចូលរួមកសាងប្រទេសជាមួយប្រជាពលរដ្ឋគ្រប់ស្រទាប់ និងអាចសម្រេចវាសនាខ្លួន ដោយខ្លួនឯង។

ការប្រជុំគ្នាជាបន្តបន្ទាប់ បានសម្រេចចេញជាអត្ថបទលក្ខន្តិកៈ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៦។ សមាជលើកទី១ របស់គណបក្សដែលបានប្រព្រឹត្តទៅនៅថ្ងៃទី ......................... បានធ្វើវិសោធនកម្មលក្ខន្តិកៈឆ្នាំ២០០៦ ហើយបាន អនុម័តអត្ថបទលក្ខន្តិកៈ ដូចតទៅ ៖

## **ជំពូក ១**
## **បញ្ញត្តិទូទៅ**

មាត្រា១ ៖ **គណបក្ស សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ** មានអក្សរកាត់ **គ. ស. ប** ជាភាសាអង់គ្លេស **LEAGUE FOR DEMOCRACY PARTY** ជាអក្សរកាត់ **LDP** ។

**មាត្រា២ ៖** គណបក្ស សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ ប្រព្រឹត្តទៅក្នុងក្របខ័ណ្ឌរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣** ៖ គណបក្ស សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ គឺជាអង្គការនយោបាយ ប្រមូលផ្ដុំប្រជាពលរដ្ឋខ្មែរគ្រប់ស្រទាប់ ដែល គោរពស្រលាញ់សេរីភាព និងប្រជាធិបតេយ្យ។ បេសកកម្មរបស់គណបក្ស គឺជួយប្រជាពលរដ្ឋឱ្យយល់ដឹង ចេះកាន់ការ ប្រទេសជាតិតាមគន្លងប្រជាធិបតេយ្យ ហើយកសាងប្រទេសបានរុងរឿងសម្បូរសប្បាយ។

**មាត្រា៤ ៖** គណបក្ស សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ មានទីស្នាក់ការកណ្តាលតាំងនៅរាជធានីភ្នំពេញ ។ ទីស្នាក់ការគណបក្ស សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ ដែលតាំងនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា មានឈ្មោះថា "ការិយាល័យរាជធានី-ខេត្ត-ក្រុង ស្រុក-ខណ្ឌ ឃុំ-សង្កាត់ "។

មាត្រា៥ ៖ គណបក្ស សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ មានរូប "**ដូង**" ជាសញ្ញាសម្គាល់ និងមានបាវចនា "**រួមគិត រួមសម្រេច រួមធ្វើ**" ។

## ជំពូក ២

## បន្ទាត់នយោបាយ

**មាត្រា៦ ៖** គណបក្ស សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ មានបន្ទាត់នយោបាយដូចតទៅ ៖

១. កាត់បន្ថយអំណាចរដ្ឋ បម្រើប្រជាពលរដ្ឋជាម្ចាស់អំណាច កសាងប្រទេសសន្តិភាព ឯករាជ្យ និងមានបូរណភាពទឹកដីពេញលេញ។

២. ប្រកាន់ខ្ជាប់គោលការណ៍ រួមគិត រួមសម្រេច រួមធ្វើ ដើម្បីស្តារ និងកសាងប្រទេសឱ្យបានសម្បូរសប្បាយ និងមានសេចក្តីថ្លៃថ្នូរ។

៣. ជួយប្រជាពលរដ្ឋឱ្យបានទទួលចំណេះដឹងទូលំទូលាយ និងកសាងធនធានមនុស្ស។

៤. ធានាតុល្យភាពអំណាច ប្រសិទ្ធភាពនីតិរដ្ឋ និងបែងចែកចំណូលរដ្ឋតាមលំដាប់អាទិភាពដើម្បីធានាសន្តិសុខ និងការបម្រើសេវាសាធារណៈជូនប្រជាពលរដ្ឋ។

៥. ជួយយុវជន បញ្ញវ័ន្ត ឱ្យមានលទ្ធភាពគ្រប់គ្រាន់ មានលក្ខណសម្បត្តិល្អប្រសើរ ដើម្បីរួមចំណែក បម្រើការងារកសាងប្រទេស។

៦. រក្សាមិត្តភាព ចំណងទាក់ទងល្អជាមួយប្រទេស និងប្រជាជាតិលើសកលលោក តាមគោលការណ៍ស្មើភាព និងផលប្រយោជន៍ទៅវិញទៅមក។

## ជំពូក ៣

## សមាជិកភាព សិទ្ធិ និងករណីយកិច្ចសមាជិក

**មាត្រា៧ ៖** ប្រជាពលរដ្ឋពេញវ័យគ្រប់រូប អាចធ្វើជាសមាជិករបស់គណបក្ស។

មាត្រា៨ ៖

១. សមាជិកគណបក្សមានសិទ្ធិស្មើគ្នា និងមានករណីយកិច្ចជួយកសាងគណបក្ស គោរពលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងរាល់សេចក្តីសម្រេចរបស់គណបក្ស។
២. សកម្មភាពរបស់សមាជិកគណបក្ស គឺសំដៅបម្រើប្រយោជន៍ប្រទេសជាតិ និងប្រយោជន៍មនុស្សទូទៅ។

**មាត្រា៩ ៖** សមាជិកភាពអាចបាត់បង់ដោយសារមរណភាព ការលាឈប់ និងការចូលជាសមាជិកគណបក្សដទៃ។

## ជំពូក ៤

## ធនធានគណបក្ស

**មាត្រា១០ ៖** ធនធានគណបក្ស គឺជាចលនវត្ថុ និងអចលនវត្ថុ ដែលបានចុះបញ្ជីសារពើភណ្ឌ។ បញ្ជីមួយច្បាប់តម្កល់នៅ អគ្គលេខាធិការដ្ឋាន និងមួយច្បាប់ទៀតនៅការិយាល័យប្រធានគណបក្ស។

១. ធនធានគណបក្សមានប្រភពពីភាគទានរបស់សមាជិក និងពីប្រភពស្របច្បាប់ផ្សេងៗទៀត។
២. របាយការណ៍ស្តីពីចំណូល ចំណាយរបស់គណបក្ស អាចផ្សព្វផ្សាយជាសាធារណៈ។
៣. សមាជិកគ្រប់រូបរបស់គណបក្សមានសិទ្ធិផ្ទៀងផ្ទាត់ ត្រួតពិនិត្យរបាយការណ៍ខាងលើនេះ លើកលែងតែបញ្ជី សារពើភណ្ឌនៃអចលនទ្រព្យ។

## ជំពូក ៥

## រចនាសម្ព័ន្ធគណបក្ស

**មាត្រា១១ ៖** រចនាសម្ព័ន្ធគណបក្ស គឺ ៖

១. សមាជគណបក្ស
២. គណៈកម្មាធិការកណ្តាល
៣. គណៈកម្មាធិការអចិន្ត្រៃយ៍
៤. ក្រុមប្រឹក្សាមូលដ្ឋាន
៥. ក្រុមប្រឹក្សាវិន័យ

### សមាជគណបក្ស

**មាត្រា១២ ៖** សមាជ ជាស្ថាប័នដឹកនាំខ្ពស់បំផុតរបស់គណបក្ស ដែលមានសមាជសាមញ្ញ និងសមាជវិសាមញ្ញ។

១. សមាជសាមញ្ញ ប្រារព្ធធ្វើជាធម្មតារៀងរាល់ប្រាំ (៥)ឆ្នាំម្តង។ សមាជសាមញ្ញត្រូវដំណើរការក្រោមអធិបតីភាពរបស់គណៈកម្មការសមាជ។

២. កូរ៉ុមសមាជសាមញ្ញ គឺពីរភាគបី (២/៣) នៃចំនួនសមាជិកសមាជ។ កូរ៉ុមនេះ ត្រូវបានកំណត់ ហើយប្រកាសដោយ គណៈកម្មការសមាជ យ៉ាងតិចមួយ (១)ថ្ងៃមុនធ្វើសមាជ។
៣. ការកំណត់ពេលវេលា របៀបវារៈការងារ និងការជ្រើសរើសគណៈកម្មការសមាជសាមញ្ញត្រូវសម្រេចដោយគណៈកម្មាធិការកណ្តាល ហើយត្រូវផ្សព្វផ្សាយយ៉ាងតិចសែសិប (៤០)ថ្ងៃមុនពេលសមាជ។ របៀបរបប និងកិច្ចការលំអិតរបស់សមាជ មានចែងក្នុងបទបញ្ញត្តិសម្រេចដោយគណៈកម្មាធិការកណ្តាល ។

**មាត្រា១៣** ៖ សមាសភាពគណៈកម្មការសមាជសាមញ្ញមានប្រាំ (៥)រូប។ ប្រធាន និងអនុប្រធានគណៈកម្មការនេះគឺជាសមាជិកគណៈកម្មាធិការកណ្តាល ដែលត្រូវជ្រើសតាំងដោយគណៈកម្មាធិការអចិន្ត្រៃយ៍។ សមាជិកបី (៣) រូបទៀត នឹងត្រូវបានជ្រើសតាំង ក្នុងសម័យប្រជុំពេញអង្គនៃគណៈកម្មាធិការកណ្តាល។
១. គណៈកម្មការសមាជសាមញ្ញមានអំណាចរំសាយអង្គសមាជមុនចប់កម្មវិធី ដែលបានគ្រោងទុក លុះត្រាតែ មានការសម្រេចបន្ទាន់របស់គណៈកម្មាធិការអចិន្ត្រៃយ៍។
២. គណៈកម្មការសមាជសាមញ្ញ ត្រូវរំសាយ ដោយស្វ័យប្រវត្តិដប់ប្រាំ (១៥)ថ្ងៃក្រោយពេលសមាជ។

**មាត្រា១៤** ៖ សមាជិកពេញសិទ្ធិនៃសមាជសាមញ្ញ គឺ ៖
១. សមាជិកគណៈកម្មាធិការកណ្តាល។
២. តំណាងការិយាល័យរាជធានី-ខេត្ត-ក្រុង ស្រុក-ខណ្ឌ ឃុំ-សង្កាត់ តំណាងសាខា និងទីប្រឹក្សាប្រធានគណបក្ស។

**មាត្រា១៥** ៖ សមាជសាមញ្ញ មានភារកិច្ច ៖
១. អនុម័តរបាយការណ៍របស់គណៈកម្មាធិការកណ្តាល របាយការណ៍របសក្រុមប្រឹក្សាវិន័យ និងការបញ្ចប់អាណត្តិ គណៈកម្មាធិការកណ្តាល អាណត្តិក្រុមប្រឹក្សាវិន័យ អាណត្តិប្រធានគណបក្ស។
២. កំណត់យុទ្ធសាស្ត្រ និងគោលនយោបាយគណបក្ស។
៣. ជ្រើសតាំងសមាជិកគណៈកម្មាធិការកណ្តាល និងជ្រើសតាំងប្រធានគណបក្ស។
៤. ធ្វើវិសោធនកម្មលក្ខន្តិកៈ និងរំលាយគណបក្ស។

**មាត្រា១៦** ៖ ភ្ញៀវចូលរួមសមាជ ត្រូវកំណត់ដោយគណៈកម្មការសមាជ។

**មាត្រា១៧** ៖ សមាជវិសាមញ្ញអាចប្រារព្ធធ្វើតាមមតិស្នើសុំពីរភាគបី (២/៣) របស់គណៈកម្មាធិការកណ្តាល។ កិច្ចការទាំងអស់របស់សមាជវិសាមញ្ញ ត្រូវសម្រេចដោយគណៈកម្មាធិការអចិន្ត្រៃយ៍។

**គណៈកម្មាធិការកណ្តាល**

**មាត្រា១៨** ៖ គណៈកម្មាធិការកណ្តាល គឺជាស្ថាប័នដឹកនាំ និងត្រួតពិនិត្យរាល់ការងារគណបក្ស ដែលត្រូវបានជ្រើសតាំងសម្រាប់អាណត្តិក្នុងចន្លោះពីសមាជសាមញ្ញមួយ រហូតដល់សមាជសាមញ្ញមួយទៀត។ ដំណើរការការងាររបស់ គណៈកម្មាធិការកណ្តាលប្រព្រឹត្តិទៅតាមបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។

**មាត្រា១៩** ៖ គណៈកម្មាធិការកណ្តាលមានភារកិច្ច ៖

១. ជ្រើសតាំង ដកហូតតួនាទីជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ សមាជិកគណៈកម្មាធិការកណ្តាល ប្រធាន-អនុប្រធានក្រុមប្រឹក្សាវិន័យ អនុប្រធានគណបក្ស អគ្គលេខាធិការ អគ្គលេខាធិការរងម្នាក់។

២. អនុវត្ត និងត្រួតពិនិត្យរាល់ការងាររបស់គណបក្ស រាប់តាំងពីការងារដែលសមាជបានអនុម័ត ឬដែលមានចែង ក្នុងលក្ខន្តិកៈ ឬបទបញ្ជាផ្ទៃក្នុង ឬសេចក្តីសម្រេចផ្សេងៗ។

៣. សម្រេច ឬកែប្រែបទបញ្ជាផ្ទៃក្នុង វចនាសម្ព័ន្ធ សេចក្តីសម្រេចផ្សេងៗ។

៤. ពន្យាររយៈកាលកំណត់ធ្វើសមាជ លើកពេលកំណត់ធ្វើសមាជ និងលុបចោលគំរោងធ្វើសមាជ។

៥. ពិនិត្យ សម្រេចកិច្ចការដែលជាសំនើរបស់គណៈកម្មាធិការអចិន្ត្រៃយ៍។

៦. គ្មានសិទ្ធិសម្រេចរំលាយខ្លួនឯង ក្រៅអង្គសមាជ។

៧. កូរ៉ុមដើម្បីដំណើរការរាល់សម័យប្រជុំពេញអង្គគឺចំនួនពីរភាគបី នៃសមាជិកគណៈកម្មាធិការកណ្តាល។

៨. រាល់ការសម្រេចរបស់គណៈកម្មាធិការកណ្តាល ត្រូវមានការគាំទ្រដោយសំឡេងហាសិបភាគរយបូកមួយនៃអ្នកចូលរួម។

**មាត្រា២០** ៖ គណៈកម្មាធិការកណ្តាលកោះប្រជុំពេញអង្គក្រោមអធិបតីភាពប្រធានគណបក្ស មិនលើសពីដប់ប្រាំ (១៥) ថ្ងៃក្រោយសមាជ ដើម្បីកំណត់ចំនួន និងជ្រើសរើស អគ្គលេខាធិការរងម្នាក់ សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ ប្រធាន-អនុប្រធានក្រុមប្រឹក្សាវិន័យ។

**មាត្រា២១** ៖ គណៈកម្មាធិការកណ្តាល កោះប្រជុំពេញអង្គក្រោមអធិបតីភាព របស់ប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍។

**គណៈកម្មាធិការអចិន្ត្រៃយ៍**

**មាត្រា២២** ៖ គណៈកម្មាធិការអចិន្ត្រៃយ៍ជាអង្គភាពប្រចាំការរបស់គណៈកម្មាធិការកណ្តាល ដែលដឹកនាំ ត្រួតពិនិត្យ និង ចាត់ចែងរាល់កិច្ចការប្រចាំថ្ងៃរបស់គណបក្ស ឬលើកសំណើជូនគណៈកម្មាធិការកណ្តាលសម្រេច។ ដំណើរការការងាររបស់ គណៈកម្មាធិការអចិន្ត្រៃយ៍ ប្រព្រឹត្តទៅតាមបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។

**មាត្រា២៣** ៖ គណៈកម្មាធិការអចិន្ត្រៃយ៍ មានសមាជិកយ៉ាងតិចប្រាំបួន(៩)រូបគឺ ប្រធានគណបក្ស អនុប្រធានគណបក្ស ពីរ(២)រូប អគ្គលេខាធិការ អគ្គលេខាធិការរងម្នាក់ (១) និងត្រូវជ្រើសតាំងបន្ថែមបួនរូប (៤) ឬច្រើនរូបទៀតចេញពីសមាជិកគណៈកម្មាធិការកណ្តាល។ អគ្គលេខាធិការរងម្នាក់ និងសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍បន្ថែមត្រូវជ្រើសតាំងដោយគណៈកម្មាធិការកណ្តាល ដែលបេក្ខភាពអ្នកទាំងនោះត្រូវបានស្នើឡើងដោយប្រធានគណបក្សក្រោយ ពីការពិគ្រោះជាមួយអនុប្រធានគណបក្សទាំងពីរ និងអគ្គលេខាធិការ។

**មាត្រា២៤** ៖ សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ ត្រូវផ្លាស់វេនគ្នាបីខែម្តង ទទួលភារកិច្ចជាប្រធានគណៈកម្មាធិការនេះ។

**មាត្រា២៥** ៖ គណៈកម្មាធិការអចិន្ត្រៃយ៍មានភារកិច្ច ៖

១. ស្នើបេក្ខជនគណៈកម្មាធិការកណ្តាលដាក់ជូនអង្គសមាជអនុម័ត។
២. សម្រេចបង្កើត ទទួលស្គាល់ ឬលុបចោលការិយាល័យរាជធានី ខេត្ត-ក្រុង ស្រុក-ខណ្ឌ ឃុំ-សង្កាត់ និងគណៈកម្មការជំនាញ។
៣. បំពេញការងារតាមការសម្រេចរបស់គណៈកម្មាធិការកណ្តាល ពិនិត្យកិច្ចការប្រចាំថ្ងៃរបស់អគ្គលេខាធិការ ក្រុមសវនកម្ម ការិយាល័យរាជធានី ខេត្ត-ក្រុង ស្រុក-ខណ្ឌ ឃុំ-សង្កាត់ និងគណៈកម្មការជំនាញ។
៤. រៀបយុទ្ធសាស្ត្រ និងគំរោងការងារ ដាក់ជូនគណៈកម្មាធិការកណ្តាល។
៥. កំណត់ជំហរគណបក្ស និងសម្រេចកិច្ចការទូទៅ ដែលមានលក្ខណៈចាំបាច់ បន្ទាន់ ឬបញ្ហាជាករណីមិនប្រក្រតី។

៦. ធ្វើសេចក្តីព្រាងខ្លឹមសារវិសោធនកម្មលក្ខន្តិកៈ សំណើកែប្រែឈ្មោះគណបក្ស សំណើរំលាយគណបក្ស និង សំណើកែប្រែរចនាសម្ព័ន្ធ។

៧. រាល់កិច្ចការ ដូចមានចែងក្នុងចំណុចប្រាំមួយ (៦) ខាងលើ ត្រូវដាក់ជូនគណៈកម្មាធិការកណ្តាលពិនិត្យសម្រេច។

៨. សម្រេចការផ្លាស់ទីតាំងស្នាក់ការកណ្តាលគណបក្ស។

៩. ស្នើគណៈកម្មាធិការកណ្តាលឱ្យជ្រើសបន្ថែមសមាជិកគណៈកម្មាធិការកណ្តាល ជ្រើសតាំង និង រំសាយក្រុម សវនកម្ម និងជ្រើសតាំងសមាជិកក្រុមប្រឹក្សាវិន័យ។។

១០. ត្រួតពិនិត្យបញ្ជាសីរាពើភណ្ឌ និងគ្រប់គ្រង ចាត់ចែងលើរាល់ធនធានរបស់គណបក្ស។

១១. សម្រេចលើរាល់ករណីសាខាគណបក្ស។

១២. សមាជិកនមីយ្លួៗនៃគណៈកម្មាធិការអចិន្ត្រៃយ៍ ត្រូវឆ្លើយពន្យល់ រាល់សំណួររបស់សមាជិក គណៈកម្មាធិការ កណ្តាល ឬក្រុមសម្ព័ន្ធយុវជន ដែលបានផ្ញើមកតាមរយៈលេខាធិការដ្ឋាន។

១៣. ជាស្ថាប័នជម្រះក្តីឧទ្ធរណ៍តែមួយគត់ បន្ទាប់ពីក្រុមប្រឹក្សាវិន័យ។

## ក្រុមប្រឹក្សាមូលដ្ឋាន

**មាត្រា២៦** ៖ ក្រុមប្រឹក្សាមូលដ្ឋាន គឺជាសេនាធិការរបស់គណបក្ស ដែលធ្វើការងារ ក្នុងភូមិសាស្ត្រទឹកដីរបស់ប្រទេស និងក្នុងស្រទាប់ប្រជាពលរដ្ឋ។ ក្រុមប្រឹក្សាមូលដ្ឋាន គឺ ៖

១. ការិយាល័យរាជធានី ខេត្ត-ក្រុង ស្រុក-ខណ្ឌ ឃុំ-សង្កាត់។

២. អង្គការមហាជន ដែលស្ម័គ្រគាំទ្រគណបក្ស។

**មាត្រា២៧** ៖ ការិយាល័យរាជធានី ខេត្ត-ក្រុង ស្រុក-ខណ្ឌ ឃុំ-សង្កាត់ មានបី (៣) លំដាប់ថ្នាក់រដ្ឋបាលគឺ ៖

១. ការិយាល័យរាជធានីខេត្ត-ក្រុង។

២. ការិយាល័យស្រុក-ខណ្ឌ។

៣. ការិយាល័យឃុំ-សង្កាត់។

**មាត្រា២៨** ៖ ការិយាល័យរាជធានី ខេត្ត-ក្រុង ស្រុក-ខណ្ឌ ឃុំ-សង្កាត់ មានទម្រង់ដូចខាងក្រោមនេះ ៖

១. រាល់ការិយាល័យរាជធានី ខេត្ត-ក្រុង ស្រុក-ខណ្ឌ ឃុំ-សង្កាត់ ត្រូវបានដឹកនាំ និងចាត់ចែងការងារ ដោយ លេខាធិការមួយរូប (១) និងលេខាធិការរងមួយរូប (១) ឬច្រើនរូប អមដោយបុគ្គលិកមួយចំនួន ដើម្បីជួយ ការងារការិយាល័យ។

២. ចំនួនសមាជិក និងចំនួនលេខាធិការរងការិយាល័យរាជធានី ខេត្ត-ក្រុង មានអាណត្តិប្រាំ (៥)ឆ្នាំ ត្រូវកំណត់ ដោយគណៈកម្មាធិការអចិន្ត្រៃយ៍។

៣. ចំនួនសមាជិក និងចំនួនលេខាធិការរងការិយាល័យស្រុក-ខណ្ឌ ឃុំ-សង្កាត់ មានអាណត្តិប្រាំ (៥) ឆ្នាំត្រូវកំណត់ដោយការិយាល័យរាជធានីខេត្ត-ក្រុង។
៤. ភារកិច្ចការិយាល័យនៃក្រុមប្រឹក្សាមូលដ្ឋាន ត្រូវកំណត់ដោយគណៈកម្មាធិការអចិន្ត្រៃយ៍។

## ក្រុមប្រឹក្សាវិន័យ

**មាត្រា២៩ ៖** ក្រុមប្រឹក្សាវិន័យ គឺជាស្ថាប័នតុលាការរបស់គណបក្ស មានសមាសភាពប្រាំ (៥)រូប មានអាណត្តិដំណាល គ្នានឹងអាណត្តិគណៈកម្មាធិការកណ្តាល។

**មាត្រា៣០ ៖** ក្រុមប្រឹក្សាវិន័យមានភារកិច្ចទទួល និងចាត់ការលើពាក្យបណ្តឹង ធ្វើការចោទប្រកាន់ និងជម្រះក្តី។ រាល់សាលក្រមចេញពីក្រុមប្រឹក្សាវិន័យ ជាសាលក្រមបិទផ្លូវឧទ្ធរណ៍ លើកលែងតែសាលក្រម ដែលសម្រេចដកហូតសមាជិកភាព ដកហូតមុខតំណែង តួនាទី ត្រូវដាក់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ពិនិត្យសម្រេច។

## ជំពូក ៦

## សាខាគណបក្ស

**មាត្រា៣១ ៖** សាខា គណបក្ស សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ គឺជាអង្គភាពនយោបាយ តំណាងគណបក្ស តាំងនៅបរទេស ហើយគោរពតាមស្មារតីនៃលក្ខន្តិកៈនេះ។ សាខាគណបក្សមានលក្ខណៈ និងដំណើរការការងារតាមស្ថានភាពជាក់ស្តែងនៅបរទេស។

## ជំពូក ៧

## ប្រធាន អនុប្រធាន អគ្គលេខាធិការ ក្រុមសវនកម្ម

### ប្រធាន អនុប្រធាន

**មាត្រា៣២ ៖** គណបក្សសម្ព័ន្ធ ដើម្បីប្រជាធិបតេយ្យ ត្រូវបានដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធាន ពីររូប ដែលជាតំណាងកំពូលរបស់គណបក្ស។ បេក្ខជនឈរឈ្មោះជាប្រធានគណបក្ស ត្រូវមានការគាំទ្រជាមុន ពីសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ យ៉ាងតិចប្រាំ (៥) រូប ឬមានការគាំទ្រជាមុន ពីសមាជិកគណៈកម្មាធិការកណ្តាលចំនួនហាសិបភាគរយ បូកមួយ (៥0% +១)។

១. អនុប្រធានពីររូប ត្រូវបានជ្រើសតាំងដោយគណៈកម្មាធិការកណ្តាល បន្ទាប់ពីការ ជ្រើសតាំងប្រធានគណបក្ស រួចហើយភ្លាម។ ប្រធានគណបក្ស ជាអ្នកស្នើបេក្ខភាពអនុប្រធាន។
២. ភារកិច្ចដឹកនាំ របស់ប្រធាន-អនុប្រធានគណបក្ស មានចែងនៅក្នុង បទបញ្ជាសម្រេចដោយគណៈកម្មាធិករាកណ្តាល។ ប្រធានគណបក្សបែងចែកភារកិច្ច ជូនអនុប្រធានគណបក្ស ដោយ

មានការយល់ព្រមពីគណៈកម្មាធិការអចិន្ត្រៃយ៍។ អនុប្រធានម្នាក់ទទួលខុសត្រូវការងារហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិគណបក្ស។

៣. អាណត្តិប្រធាន និងអនុប្រធានគណបក្សមានរយៈពេលពីសមាជសាមញ្ញមួយ ទៅសមាជសាមញ្ញមួយទៀត លើកលែងមានបញ្ហាមិនប្រក្រតី។

៤. គ្មានជនណាម្នាក់ត្រូវបានជ្រើសតាំងជាលើកទីបី ឱ្យធ្វើជាប្រធានគណបក្ស លើកលែងតែបេក្ខភាពជននោះ មានការគាំទ្រជាមុនពីគណៈកម្មាធិការអចិន្ត្រៃយ៍។

**មាត្រា៣៣** ៖ ប្រធានស្តីទីគណបក្សអាចត្រូវជ្រើសតាំងដោយគណៈកម្មាធិការកណ្តាលមិនលើសពីដប់ប្រាំ (១៥)ថ្ងៃក្រោយមរណភាពប្រធានគណបក្ស ឬករណីដែលជាសំណើរបស់គណៈកម្មាធិការអចិន្ត្រៃយ៍។ ករណីដូចនេះ អនុប្រធានមួយ (១) រូប ត្រូវបានគណៈកម្មាធិការកណ្តាលតែងតាំងជាប្រធានស្តីទីគណបក្សនាសម័យប្រជុំពេញអង្គ។

## អគ្គលេខាធិការ

**មាត្រា៣៤** ៖ អគ្គលេខាធិការ គឺជាតំណាងគណៈកម្មាធិការអចិន្ត្រៃយ៍ បំពេញកិច្ចការ ដែលជាជីវភាពប្រចាំថ្ងៃរបស់គណបក្ស។

១. អគ្គលេខាធិការ ត្រូវបានជ្រើសតាំងដោយគណៈកម្មាធិការកណ្តាល បន្ទាប់ពីការជ្រើសតាំងប្រធានគណបក្ស រួចហើយភ្លាម។ ប្រធានគណបក្ស ជាអ្នកស្នើបេក្ខភាពអគ្គលេខាធិការ។

២. ភារកិច្ចរបស់អគ្គលេខាធិការត្រូវកំណត់ដោយគណៈកម្មាធិការអចិន្ត្រៃយ៍។

៣. អាណត្តិអគ្គលេខាធិការមានរយៈពេលពីសមាជសាមញ្ញមួយទៅសមាជសាមញ្ញមួយទៀត លើកលែងតែកើត មានករណីមិនប្រក្រតី ដែលត្រូវយោងតាមសេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍។

៤. អគ្គលេខាធិការជ្រើសរើសសមាសភាពអគ្គលេខាធិការរង ហើយដាក់ជូនគណៈកម្មាធិកាអចិន្ត្រៃយ៍សម្រេច។ អគ្គលេខាធិការរងម្នាក់ ជាសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍។ អគ្គលេខាធិការបែងចែកភារកិច្ចជូន អគ្គលេខាធិការរង ដោយមានការយល់ព្រមពីគណៈកម្មាធិការអចិន្ត្រៃយ៍។

## ក្រុមសវនកម្ម

**មាត្រា៣៥** ៖ យោងមាត្រា២៥.៩ ក្រុមសវនកម្មមានសមាសភាពបីរូប គឺនាយកសវនកម្មមួយរូប និងសមាជិកពីររូប មាន ការិយាល័យតាំងនៅទីស្នាក់ការកណ្តាលគណបក្ស។ អង្គភាពសវនកម្ម អាចមានបុគ្គលិក សម្រាប់បម្រើការងារក្នុងការិយាល័យ។

**មាត្រា៣៦ ៖** ក្រុមសវនកម្មត្រួតពិនិត្យចំណូល ចំណាយ និងបញ្ជីសារពើភណ្ឌ ជាធម្មតាមួយឆ្នាំម្តង។ ចំណាត់ការត្រួត ពិនិត្យខុសពីធម្មតា អាចធ្វើបាន តាមករណីដែលជាសំណើរបស់គណៈកម្មាធិការអចិន្ត្រៃយ៍។

**មាត្រា៣៧ ៖** របាយការណ៍សវនកម្មអាចផ្សព្វផ្សាយជាសាធារណៈ។

**មាត្រា៣៨ ៖** ក្រុមសវនកម្មអាចទទួលពាក្យបណ្តឹង ហើយដាក់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍សម្រេច។

**មាត្រា៣៩ ៖** ក្រុមសវនកម្មអាចស្នើគណៈកម្មាធិការអចិន្ត្រៃយ៍សម្រេចចាត់ការលើរាល់ករណីចំណូល-ចំណាយ។

**មាត្រា៤០ ៖** អាណត្តិការងារក្រុមសវនកម្មមានរយៈពេលពីសមាជមួយ ទៅសមាជមួយទៀត លើកលែងមានករណីមិន ប្រក្រតី ដោយយោងតាមសេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍។

## ជំពូក ៨
## អវសានបញ្ញត្តិ

**មាត្រា៤១ ៖** យោងមាត្រា១៥។៤ ក្នុងករណីដែលអង្គសមាជអនុម័តរំលាយគណបក្សជាស្ថាពរហើយនោះ អង្គសមាជ ដដែលនេះ ត្រូវសម្រេចភ្លាមជម្រះបញ្ជីទ្រព្យសម្បត្តិគណបក្ស។

**មាត្រា៤២ ៖** លក្ខន្តិកៈនេះត្រូវបានសមាជលើកទីមួយអនុម័ត និងមានសុពលភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាដោយ ប្រធានគណបក្ស។

រាជធានីភ្នំពេញ ថ្ងៃទី..........ខែ............... ឆ្នាំ ២០១១